# អនុសាសន៍ឯកឧត្តម ស ខេង
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
# ក្នុងកិច្ចប្រជុំក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ
# ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស
# និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ
# (០៧ ខែវិច្ឆិកា ឆ្នាំ២០០៧)

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ថ្ងៃនេះក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានដំណើរការកិច្ចប្រជុំលើកទី១ ក្នុងក្របខ័ណ្ឌជាតិទាំងមូល ដើម្បីធ្វើការត្រួតពិនិត្យវាយតម្លៃ និងលើកទិសដៅផែនការសកម្មភាព បន្ទាប់ពីរាជរដ្ឋាភិបាលបង្កើតបានរយៈពេល ៣ខែ (៨ សីហា ឆ្នាំ២០០៧) និងបន្ទាប់ពីយន្តការនៅថ្នាក់មូលដ្ឋានបានរៀបចំរួចស្រេចបាច់ជាបង្គួរ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត តំណាងអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ដែលបានឆ្លៀតឱកាសចូលរួមក្នុងវិទិការដ៏មានសារៈសំខាន់នាពេលនេះ ។

អំពើជួញដូរ និងការកេងប្រវ័ញ្ចនានាលើមនុស្ស គឺជាសកម្មភាពដែលកើតមានឡើងក្នុងពិភពលោកជាយូរលង់ណាស់មកហើយក្រោមរូបភាព និងទំរង់ផ្សេងៗគ្នា ។ ទម្រង់បែបទាសភាពនានាប្រកបដោយរចនាសម្ព័ន្ធច្បាស់លាស់ ដូចជាការកេណ្ឌទាសករនៅក្នុង និងឆ្លងដែន ដើម្បីទាញយកផលចំណេញតាមរយៈការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ការបង្ខិតបង្ខំអោយធ្វើការងារដោយផ្តល់កំរៃតិចតួច ឬគ្មានកំរៃក្នុងលក្ខ័ណ្ឌការងារលំបាក និងការបំពារបំពានផ្លូវភេទ ជាពិសេសចំពោះស្ត្រី និងកុមារ សុទ្ធសឹងជាបាតុភូតប្រវត្តិសាស្ត្រដែលធ្លាប់កើតមាន ។

ទំនើបនីយកម្ម ជាពិសេសសកលភាវូបនីយកម្មនៃរបត់ប្រវត្តិសាស្ត្រដ៏ឆាប់រហ័ស រួមទាំងការវិវត្តន៍ផ្នែកវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច បានធ្វើអោយបាតុភូតប្រវត្តិសាស្ត្រជាច្រើនមានការផ្លាស់ប្តូរជាទូទៅ ។ ដោយឡែករូបភាព និងទំរង់នៃការជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មឆ្លងដែនមួយក្នុងចំណោមបទឧក្រិដ្ឋកម្មឆ្លងដែននានាក៏មានការផ្លាស់ប្តូរផងដែរ ។ អំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សនាយុគសម័យបច្ចុប្បន្នបាននិងកំពុងកើតឡើងក្រោមផ្ទាកជំនួញ និងមុខរបរស្របច្បាប់

ដោយរាប់បញ្ចូលទាំងការបញ្ជូនពលករទៅបរទេស ការងារក្នុងឧស្សាហកម្មគ្មានផ្សែង ការស្វែងរកការតាំងទីលំនៅថ្មី អាជីវកម្មនេសាទ របរសុំទាន ការបំរើក្នុងផ្ទះ និងការរៀបអាពាហ៍ពិពាហ៍ ។ល។ និង ។ល។

អំពើជួញដូរ ការកេងប្រវ័ញ្ចពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ គឺជាសកម្មភាពមួយដែលទទួលការថ្កោលទោសជាសកលរបស់រដ្ឋាភិបាល និងមនុស្សភាគច្រើននៅលើពិភពលោកថា ជាអំពើអមនុស្សធម៌ អសីលធម៌ និងជាសកម្មភាពគួរជៀសវាង ហើយអ្នកប្រព្រឹត្តត្រូវតែទទួលទោសទណ្ឌយ៉ាងធ្ងន់ធ្ងរតាមច្បាប់ ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក**

រាជរដ្ឋាភិបាលកម្ពុជាមានជំហរ ការប្តេជ្ញាចិត្ត និងឆន្ទៈដ៏ខ្ពង់ខ្ពស់ក្នុងការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរ ការកេងប្រវ័ញ្ចលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។ ឆ្លងតាមស្មារតីនេះ ផែនការជាតិ និងយន្តការជាច្រើនត្រូវបានបង្កើតឡើង សំរាប់ទទួលខុសត្រូវ និងដោះស្រាយចំពោះបញ្ហាប្រឈមនេះ ។

ថ្ងៃនេះដើម្បីធ្វើអោយកាន់តែជាក់ស្តែងថែមទៀត និងក្នុងគោលដៅផ្សឹយន្តការនានានៅថ្នាក់ជាតិ ជាពិសេសពង្រឹងយន្តការអនុវត្តនៅថ្នាក់មូលដ្ឋានអោយកាន់តែរឹងមាំ និងមានប្រសិទ្ធិភាព និងក្នុងគោលបំណងស្វែងរកមធ្យោបាយដោះស្រាយ និងសហប្រតិបត្តិការមិនត្រឹមក្របខ័ណ្ឌផ្ទៃក្នុងរបស់យើងប៉ុណ្ណោះទេ ថែមទាំងក្នុងក្របខ័ណ្ឌសហគមន៍តំបន់ និងពិភពលោក ដើម្បីធ្វើអោយប្រជាពលរដ្ឋយើងទាំងអស់គ្នាទទួលបានសិទ្ធិជាមូលដ្ឋាន ចាកផុតពីទាសភាពសម័យថ្មី និងបង្កលក្ខណៈអោយពួកគេមានលទ្ធភាពដំណើរការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃដោយសុខសាន្ត ក្រោមដំបូលច្បាប់ និងសណ្តាប់ធ្នាប់ ។

លេខាធិការដ្ឋាន នៃក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានរាយការណ៍ជូនអង្គប្រជុំអំពីកិច្ចការសំខាន់ៗជាច្រើនដែលក្រុមការងារបានដំណើរការកន្លងមក អំពីការរៀបចំយន្តការនៅថ្នាក់មូលដ្ឋាន និងធ្វើការត្រួតពិនិត្យវាយតម្លៃអំពីកិច្ចប្រតិបត្តិការកន្លងមក ព្រមទាំងលើកឡើងនូវទិសដៅសកម្មភាពសំរាប់ពេលខាងមុខ ។ អង្គប្រជុំក៏បានស្តាប់នូវបទអន្តរាគមន៍របស់ឯកឧត្តមអភិបាលខេត្ត-ក្រុងចំណុះទាំង **៥** ។ ទន្ទឹមនេះខ្ញុំក៏សូមអបអរសាទរ និងគាំទ្រនូវមតិផ្តួចផ្តើមរបស់ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលស្នើសុំច្របាច់បញ្ចូលលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ ជាមួយលេខាធិការដ្ឋានក្រុមការងារ ដើម្បីអោយកិច្ចការស្ថិតនៅក្នុងគន្លងបន្ទាត់តែមួយ និងស្ថិតនៅក្រោមឆ័ត្រតែមួយ ។

ដើម្បីធ្វើអោយបានសំរេចជោគជ័យនូវផែនការសកម្មភាពដែលបានប្រកាសជូនរួចមកហើយ ក្នុងឱកាសនេះ ខ្ញុំសូមឯកឧត្តម លោកជំទាវ លោកស្រី អស់លោក យកចិត្តទុកដាក់ទៅលើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

១-លេខាធិការដ្ឋានក្រុមការងារ ត្រូវជួបជុំជាបន្ទាន់ជាមួយក្រុមការងារថ្នាក់ជាតិ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ព្រមទាំងដៃគូពាក់ព័ន្ធនានា ដើម្បីច្របាច់បញ្ចូលគ្នាអោយទៅជាលេខាធិការដ្ឋានរួមមួយ ដោយរៀបចំអោយបានច្បាស់លាស់អំពីសមាសភាព និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋានរួមនេះ ។

២-ឯកឧត្តមអភិបាលខេត្ត-ក្រុង ដែលជាគណៈបញ្ជាការឯកភាពនៅថ្នាក់ខេត្ត-ក្រុង ត្រូវរៀបចំអោយបានចប់ជាស្ថាពរក្បាលម៉ាស៊ីនក្រុមការងារនៅថ្នាក់ខេត្ត និងជាពិសេសនៅថ្នាក់ខ័ណ្ឌ-ស្រុក ដើម្បីជំរុញដឹកនាំកិច្ចការនេះអោយក្លាយជាចលនារួមមួយនៅទូទាំងប្រទេស ។

ខេត្ត-ក្រុងនិមួយៗ ត្រូវរៀបចំអោយមានបណ្តាញផ្តល់ពត៌មាន និងរបាយការណ៍ដោយឡែកមួយអំពីកិច្ចការនេះ ពីស្រុកមកខេត្ត និងពីខេត្តមកថ្នាក់កណ្តាល ដើម្បីអោយទិន្នន័យបានឯកភាពគ្នា មិនមែននគរបាលធ្វើដោយឡែក មន្ទីរនារី ឬសង្គមកិច្ច ធ្វើដោយឡែកនោះទេ ។ មួយសប្តាហ៍ត្រូវរាយការណ៍អំពើលទ្ធផលការងារនៅរៀងរាល់ដើមសប្តាហ៍និមួយៗ និងត្រូវមានរបាយការណ៍ជាប្រចាំខែ ត្រីមាស ឆមាស ជូនមកលេខាធិការដ្ឋាន ។

៣-សូមស្នើក្រសួងយុត្តិធម៏ជំរុញអោយតុលាការខេត្ត-ក្រុងនិមួយៗចាប់អារម្មណ៍ និងកំណត់កម្មវិធីការងារ ជាពិសេសយ៉ាងហោចណាស់មួយសប្តាហ៍ត្រូវយកសំណុំរឿងមួយករណីពាក់ព័ន្ធដល់ការជួញដូរ ការធ្វើអាជីវកម្មពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីបើកសវនាការវិនិច្ឆ័យទោស ។

៤-ក្រុមការងារខេត្ត-ក្រុង ស្រុក-ខ័ណ្ឌទាំងអស់ ត្រូវរៀបចំផែនការសកម្មភាពជាក់ស្តែង ដោយផ្អែកលើផែនការសកម្មភាពដែលក្រុមការងារថ្នាក់កណ្តាលបានលើកឡើង ក្នុងនោះត្រូវយកចិត្តទុកដាក់ប្រមូលផ្តុំដោះស្រាយចំណុចដែលលេចធ្លោក្នុងភូមិសាស្រ្តរបស់ខ្លួន ។ រាល់ការងារសំខាន់ៗដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងស្ថាប័ន ឬយន្តការនៅថ្នាក់ជាតិណាមួយ គណៈបញ្ជាការឯកភាពខេត្ត-ក្រុងត្រូវទំនាក់ទំនងដោយផ្ទាល់ដើម្បីសុំគោលការណ៍ ឬសហការដោះស្រាយ ដោយមិនទុកអោយរឿងហេតុ ឬបាតុភាពទាំងនោះរីករាលដាល ឬជះឥទ្ធិពលមិនល្អដល់សង្គមជាតិ ឬដល់អន្តរជាតិ ។

៥-លេខាធិការដ្ឋាន និងអាជ្ញាធរដែនដីត្រូវចាប់អារម្មណ៍ និងសហការជាមួយស្ថាប័នពាក់ព័ន្ធធ្វើការត្រួតពិនិត្យ និងតាមដានការជ្រើសរើសពលករដើម្បីទៅបំរើសេវាផ្សេងៗនៅក្រៅប្រទេស ក៏ដូចជាការរៀបអាពាហ៍ពិពាហ៍ ដើម្បីជៀសវាងការឆ្លៀតយកមុខរបរស្របច្បាប់នេះឃុបឃិតប្រព្រឹត្តអំពើជួញដូរ ឬអាជីវកម្មផ្លូវភេទ ។

៦-បន្តសហការការអោយបានល្អជាមួយប្រទេសជាដៃគូរ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល អនុវត្តអោយមានប្រសិទ្ធិភាពអនុសញ្ញា ពិធីសារ ឬអនុស្សារណៈសំដៅពង្រឹង និងលើកកំពស់សមត្ថភាពដល់

មន្ត្រីអនុវត្តច្បាប់ ជាពិសេសការងារស៊ើបអង្កេយនិតិវិធីក្នុងការប្រមែប្រមូលភស្តុតាង និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

៧-ត្រូវខិតខំពង្រឹងវិន័យផ្ទៃក្នុង ខិតខំលុបបំបាត់បាតុភាពអសកម្ម ព្រមទាំងកែលំអរការងារ សំដៅធានាបានអធិបតេយ្យក្នុងនាមអាជ្ញាធរនៅនឹងកន្លែង ទន្ទឹមនោះត្រូវមានការដាក់វិន័យយ៉ាងម៉ឺងម៉ាត់ចំពោះបុគ្គលណាដែលប្រព្រឹត្តខុសឆ្គង ឬមានការរំលោភបំពានទៅលើភារកិច្ច និងច្បាប់ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហការ និងការគាំទ្ររបស់បណ្តាប្រទេសជាមិត្ត និងដៃគូរអភិវឌ្ឍន៍នានាដល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាលកន្លងមក និងសូមអំពាវនាវមេត្តាជួយឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តដល់យើងខ្ញុំបន្តទៀត ជាពិសេសការកសាងសមត្ថភាព ការឃោសនាអប់រំ និងការធ្វើសមាហរណកម្មទៅក្នុងសង្គម ដើម្បីសំរេចទិសដៅចុងក្រោយប្រជាពលរដ្ឋកម្ពុជា ទាំងក្មេង ចាស់ ប្រុស ស្រី រស់នៅក្នុងភាពសុខដុមរម្យនា ចាកផុតពីហានិភ័យដែលបណ្តាលមកពីអំពើជួញដូរ ការកេងប្រវ័ញ្ចពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ ។

សូមជូនពរឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ប្រកបតែនឹងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមប្រកាសបិទអង្គប្រជុំ ។

***សូមអរគុណ!***